**ធនាគារជាតិ នៃ កម្ពុជា**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ.................................................

# សេចក្តីប្រកាសព័ត៌មាន

អនុលោមតាមច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា ច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងប្រកាសស្តីពីកាតព្វកិច្ចចុះបញ្ជីរបស់ប្រតិបត្តិករមីក្រូហិរញ្ញវត្ថុ និងការស្នើសុំអាជ្ញាប័ណ្ណរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ លេខធ៧-០២-៤៩ ប្រ.ក ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០២ ធនាគារជាតិនៃកម្ពុជា សូមជម្រាបជូន លោក លោកស្រី ជ្រាបថា ការដាក់ពាក្យស្នើសុំចុះបញ្ជីជាប្រតិបត្តិករឥណទានជនបទនៅធនាគារជាតិនៃកម្ពុជា ពុំតម្រូវឲ្យបង់កម្រៃអ្វីទាំងអស់ ។ កន្លងមកធនាគារជាតិនៃកម្ពុជា ពុំដែលបានប្រគល់សិទ្ធជូនទៅស្ថាប័នឬបុគ្គលណាមួយក្នុងការយកកម្រៃសេវា ឬទំនាក់ទំនង ឬបំពេញសំណុំឯកសារដាក់ពាក្យស្នើសុំចុះបញ្ជីជាប្រតិបត្តិករឥណទានជនបទ នៅធនាគារជាតិនៃកម្ពុជាឡើយ ។

ដើម្បីធានាបាននូវប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព ក្នុងការផ្តល់សេវាជូនសាធារណៈជន និងដើម្បីចៀសវាងនូវបាតុភាពមិនប្រក្រតីពីជនខិលខូចមួយចំនួនបានឆ្លៀតឱកាសកេងចំណេញ ធនាគារជាតិនៃកម្ពុជា សូមជំរាបជូនដល់អង្គការមិនមែនរដ្ឋាភិបាល សមាគម និងអង្គភាពនានា ដែលបានដាក់ពាក្យរួចហើយ តែមិនទាន់បានបំពេញសំណុំឯកសារត្រឹមត្រូវតាមលក្ខខណ្ឌកំណត់របស់ធនាគារជាតិនៃកម្ពុជា សូមទាក់ទងសាកសួរព័ត៌មាននិងបំពេញសំណុំឯកសារដោយផ្ទាល់មកនាយកដ្ឋានអាជ្ញាប័ណ្ណ នៃធនាគារជាតិនៃកម្ពុជា តាមរយៈមន្ត្រីទទួលបន្ទុកទំនាក់ទំនង ៖

- **លោកស្រី ខៀវ បុប្ផាភួង** — **ប្រធាននាយកដ្ឋានអាជ្ញាប័ណ្ណ**
  ទូរស័ព្ទលេខ ៖ ០១២ ៨៧០ ៩១០
- **លោក ពូ ឃាងហុង** — **អនុប្រធាននាយកដ្ឋានអាជ្ញាប័ណ្ណ**
  ទូរស័ព្ទលេខ ៖ ០១១ ៧១៧ ៧១៧ , ០៩៧ ៧ ៧១៧ ៧១៧

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម លោក លោកស្រី មេត្តាជ្រាបជាព័ត៌មាន ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៥

ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧